៥៥/៦

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សំណុំរឿងរដ្ឋប្បវេណី
លេខ : ១៣៩
ចុះថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០១៣
សាលដីកា
លេខ : ១៨៦ "ង"
ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៤

## សាលដីកា

## នាមនាមប្រជារាស្ត្រខ្មែរ

តុលាការកំពូល

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នាសវនាការជាសាធារណៈនៅថ្ងៃទី ២០ ខែមីនា ឆ្នាំ ២០១៤។

**សមាសភាពក្រុមប្រឹក្សាជំនុំជម្រះ**

១-ឯកឧត្តម [redacted] ជាប្រធាន
២-លោកស្រី ជាចៅក្រម
៣-លោក ជាចៅក្រម
៤-លោក ជាចៅក្រម
៥-លោក ជាចៅក្រម

**ក្រឡាបញ្ជី**

លោកស្រី [redacted]

**តំណាងមហាអយ្យការ**

លោក [redacted] ជាព្រះរាជអាជ្ញា

**ដើមចោទៈ**លោក [redacted] ហៅឪ "ចុងបណ្ដឹងសាទុក្ខ" អាយុ ៣០ឆ្នាំ ជាតិខ្មែរ មុខរបរមន្ត្រីអាជ្ញាធរ អប្សរា មានទីលំនៅសព្វថ្ងៃ ភូមិខ្នា ឃុំជ្រាង ក្រុងសៀមរាប ខេត្តសៀមរាប ។ ផ្ទេរឱ្យប្រពន្ធឈ្មោះ ខាន់ លីណា

**មេធាវី :** លោក [redacted] តំណាងដោយអាណត្តិ

**ចុងចម្លើយៈ**លោក [redacted] តៃ "ម្ចាស់បណ្ដឹងសាទុក្ខ" អាយុ ៦៣ឆ្នាំ ជាតិខ្មែរ មុខរបរធ្វើស្រែ មានទីលំនៅ


មហាវិថី សម្ដេចសុធារស, សង្កាត់ចតុមុខ, ខណ្ឌដូនពេញ, កម្ពុជា Sothearos Blvd, Sangkat Chatomuk, Khan Daun Penh, Cambodia

Scanned with CamScanner

សព្វថ្ងៃភូមិប្រម៉ាត់ដី ឃុំស្រយូវ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ ។

**មេធាវី : លោក [redacted] តំណាងដោយអាណាតិ**

**<u>អំពីវិវាទ</u> :-ប្តឹងទាមទារប្រាក់**

**<u>អំពីអង្គហេតុ និង ចំណុចវិវាទ:</u>**

**ក-<u>អំពីអង្គហេតុជាមូលហេតុនៃការទាមទារ:</u>**

តាមពាក្យបណ្តឹងរបស់ដើមចោទឈ្មោះ[redacted]ហៀវឌី ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ២០១១ ថា កាលពីថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០១០ ឈ្មោះ [redacted]តែ បានទៅខ្ចីចងការប្រាក់ពីខ្លួន និង ប្រពន្ធចំនួន ២.០០០ដុល្លា"ពីរពាន់ដុល្លា"ដោយសន្យាអោយការប្រាក់៣%/១ខែ និង សន្យាសងគ្រប់ចំនួននៅថ្ងៃទី១៦ ខែ មិថុនា ឆ្នាំ ២០១០។ លុះដល់ថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០១០ ឈ្មោះ [redacted] តែ បានទៅខ្ចីចងការប្រាក់ពីខ្លួនចំនួន ២.០០០ដុល្លា"ពីរពាន់ដុល្លា"ទៀត ដោយគិតការប្រាក់ ៣%/១ខែ និង ចុងក្រោយ [redacted] តែ បានមកចងការប្រាក់ពីខ្លួនចំនួន ៤០០ដុល្លា(បួនរយដុល្លា)ទៀត ដោយសន្យាអោយការប្រាក់ ៣% ក្នុងមួយខែដូចគ្នា។ តែចាប់ពីពេលនោះមក [redacted] តែ ពុំបានយកប្រាក់មកសងតាមកិច្ចសន្យាទេ ទើបខ្លួនដាក់ពាក្យបណ្តឹងសុំអោយប្រធានសាលាដំបូងខេត្តមេត្តាចេញសាលក្រមអោយឈ្មោះ[redacted] តែ សងប្រាក់ដើមសរុបចំនួន ៤.៤០០ដុល្លា"បួនពាន់បួនរយដុល្លា" និង ការប្រាក់ ៣%/១ខែ គិតពីថ្ងៃចង ការរហូតដល់ថ្ងៃសងការប្រាក់គ្រប់ចំនួន និង ទាមទារជម្ងឺចិត្តចំនួន ០៤លានរៀល ទើបសុខចិត្ត។

**បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ១៤"រ"ចុះថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០១១ របស់សាលាដំបូងខេត្តកំពង់ធំ សំរេច :**

១-សំរេចអោយឈ្មោះ [redacted] តែ សងប្រាក់ដើមចំនួន ២.៤០០ដុល្លា"ពីរពាន់បួនរយដុល្លា"អាមេរិក ទៅអោយឈ្មោះ ហេង ហៀវឌី តាមកិច្ចសន្យាចុះថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០១០ និង កិច្ចសន្យាចុះថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០១០។ សេចក្តីសំរេចត្រង់ចំណុចទី ១នេះ អាចអនុវត្តជាបណ្តោះអាសន្នបាន។

២-សំរេចអោយឈ្មោះ [redacted] តែ សងប្រាក់ដើមចំនួន ២.០០០ដុល្លា"ពីរពាន់ដុល្លា"អាមេរិកទៅឱ្យឈ្មោះ ហេង ហៀវឌី តាមកិច្ចសន្យា ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០១០ ចាប់ពីថ្ងៃសាលក្រមចូលជាស្ថាពរ។

៣-សំរេចអោយឈ្មោះ [redacted] តែ សងការប្រាក់ ៥% ក្នុងមួយឆ្នាំលើប្រាក់ដើម សរុប ៤.៤០០ដុល្លា "បួនពាន់បួនរយដុល្លា"អាមេរិក ទៅអោយឈ្មោះ [redacted] ហៀវឌី គិតចាប់ពីថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០១០ រហូតដល់ថ្ងៃសងប្រាក់គ្រប់ចំនួន តាមមាត្រា៥៩ នៃក្រឹត្យច្បាប់លេខ ៣៨ក្រ.ច ស្តីពីកិច្ចសន្យា និង ការទទួលខុសត្រូវក្រៅកិច្ចសន្យា។

៤-សំរេចអោយឈ្មោះ [redacted] តែ សងប្រាក់ថ្លៃខាតបង់ពេលវេលាចំនួន ២.៥០០.០០០រៀល"ពីរលាន

ប្រាំសែនរៀល" អោយទៅឈ្មោះ [redacted] ហឿវឌី ចាប់ពីសាលក្រមស្ថាពរតទៅ ។

៥-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ ។

៦-សាលក្រមនេះជំនុំជំរះនៅថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១១ និង ប្រកាសជាសាធារណៈនៅថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០១១ចំពោះភាគីចុងចម្លើយ កំបាំងមុខដើមចោទ ចាត់ទុកជាចំពោះមុខ ។ ទុកសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

*សាលក្រមនេះ ត្រូវបានឈ្មោះ [redacted] រ៉ែត ប្តឹងឧទ្ធរណ៍តាមបណ្តឹងលេខ ៣០ ចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១១ ត្រង់ចំណុចនៃសេចក្តីសំរេចទាំងមូល ។*

*សាលក្រមនេះ ត្រូវបានឈ្មោះ [redacted] ហឿវឌី ប្តឹងឧទ្ធរណ៍តាមបណ្តឹងលេខ ០១ ចុះថ្ងៃទី ០៣ ខែ មករា ឆ្នាំ ២០១២ ត្រង់ចំណុចទី ៣ និងទី ៤ នៃសេចក្តីសំរេច ។*

**បានឃើញសាលដីការដ្ឋប្បវេណីលេខ ០៨"ក្រប" ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១៣ របស់សាលាឧទ្ធរណ៍ សំរេច :**

១-ប្រានចោលពាក្យបណ្តឹងឧទ្ធរណ៍របស់ [redacted] រ៉ែត ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០១១ ចោល ។

២-ប្រានចោលពាក្យបណ្តឹងឧទ្ធរណ៍របស់ឈ្មោះ [redacted] ហឿវឌី ចុះថ្ងៃទី ០៣ ខែ មករា ឆ្នាំ ២០១២ ចោល ។

៣-តម្កល់សាលក្រមរដ្ឋប្បវេណីលេខ ១៤"ឆ" ចុះថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០១១ របស់សាលាដំបូងខេត្តកំពង់ធំ ទុកជាបានការពេញទាំងមូល ។

៤-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ឈ្មោះ [redacted] រ៉ែត និង [redacted] ហឿវឌី ។

៥-សាលដីកានេះប្រកាសជាសាធារណៈនៅថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១៣ បើកផ្លូវសាទុក្ខក្នុងកំណត់ច្បាប់ ។

*សាលដីកានេះ ត្រូវបានឈ្មោះ [redacted] កែវលីម មេធាវីតំណាងដោយអាណត្តិអោយឈ្មោះ [redacted] រ៉ែត ប្តឹងសាទុក្ខតាមបណ្តឹងលេខ ១៨៧ ចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១៣ ត្រង់ចំណុចនៃសេចក្តីសំរេចទាំងមូល ។*

**ខ-<u>អំពីសេចក្តីថ្លែងការណ៍របស់គូភាគី</u> :**

**ឈ្មោះ [redacted] រ៉ែត ធ្វើសេចក្តីថ្លែងការណ៍ថា :** អង្គហេតុដើម គឺកើតចេញពីការទិញលក់ដី និង កក់ប្រាក់ គឺខ្លួនមិនបានខ្ចីប្រាក់ [redacted] ហឿវឌី ទេ ប្រាក់ ៥.០០០ ដុល្លានេះជាប្រាក់កក់ដីអោយឈ្មោះ សូត្រ ប៊ុណ្ណោះ ។ខ្លួនទទួលស្គាល់តែកិច្ចសន្យាចុះថ្ងៃទី២៥-០៦-២០១០ ដែលខ្លួនបានផ្តិតមេដៃនិងទទួលបានប្រាក់ ៤០០ ដុល្លាមែន ដោយឡែកកិច្ចសន្យាចុះថ្ងៃទី ០៨-០៦-២០១០ ខ្លួនបានផ្តិតមេដៃមែន តែមិនបានទទួលប្រាក់ ២.០០០ ដុល្លានោះទេ ឯកិច្ចសន្យាចុះថ្ងៃទី ០៩-០៦-២០១០ ខ្លួនមិនបានផ្តិតមេដៃទេ ។

**ឈ្មោះ [redacted] ធ្វើសេចក្តីថ្លែងការណ៍ថា :** កិច្ចសន្យាទាំងបីនេះធ្វើនៅខេត្តសៀមរាប មានទាំងប្រាក់ដើម និង ការប្រាក់ ។ កិច្ចសន្យាទាំងបីនេះ គឺជាស្នាមមេដៃ [redacted] រ៉ែត ទាំងអស់ ឯរឿងពាក់ព័ន្ធនិងការរកស៊ីរបស់គាត់ មិនពាក់ព័ន្ធនឹងការរកស៊ីចងការប្រាក់របស់ខ្លួនទេ ។

Scanned with CamScanner

លោក [redacted] មេធាវីតំណាងដោយអាណត្តិអោយលោក [redacted] តៃ ធ្វើសេចក្តីថ្លែងការណ៍ថា : ចម្លើយរបស់ដើមចោទថា ជាការខ្ចីចងការប្រាក់នោះ គឺមិនពិតទេ ព្រោះអង្គហេតុពិតដូចដែលកូនក្តីខ្លួនបានលើកឡើងប្រាកដមែន ។ ចំពោះកិច្ចសន្យាទាំងបីបន្តបន្ទាប់គ្នានេះ សួរថា បើកូនក្តីខ្លួនមិនទាន់សងប្រាក់ក្នុងកិច្ចសន្យាលើកទី ១ផង ហេតុអីអោយកូនក្តីខ្លួនខ្ចីបន្ថែមម្តងហើយ ម្តងទៀត បើកូនក្តីខ្លួនក្រីក្រ រកប្រាក់ឯណាមកសង ។ កូនក្តីខ្លួនទទួលស្គាល់តែប្រាក់ ៤០០ដុល្លាអាមេរិកប៉ុណ្ណោះដែលគាត់បានទទួល ។ កិច្ចសន្យាខុសច្បាប់ជាកិច្ចសន្យាមានវិការៈ មានចរិតកេងបន្លំលើចុងចម្លើយ ។

**សំណូមពរ :** -លុបចោលសាលក្រមរបស់សាលាដំបូងខេត្តកំពង់ធំ

-សុំបដិសេធចោលសាលដីកាសាលាឧទ្ធរណ៍ទាំងមូល

លោក [redacted] មេធាវីតំណាងដោយអាណត្តិអោយលោក [redacted] ហៀវឌី ធ្វើសេចក្តីថ្លែងការណ៍ថា : អង្គហេតុដើម គឺកើតចេញពីកិច្ចសន្យាខ្ចីចងការប្រាក់ គឺពុំមានពាក់ព័ន្ធនឹងអង្គហេតុលក់ទិញដីដូចការលើកឡើងរបស់ចុងចម្លើយទេ ។

តាមកិច្ចសន្យាទាំងបី សរុបទឹកប្រាក់មានចំនួន ៤៤០០ដុល្លា ដោយបានបង់ការប្រាក់អោយកូនក្តីខ្លួនបានចំនួន ២៥០ដុល្លា ក្រោយមកក៏លែងបង់ ទើបកូនក្តីខ្លួនប្តឹងមកតុលាការកំពូល ។

តាមកិច្ចសន្យាទាំងបីបានបញ្ជាក់ច្បាស់ថា ចុងចម្លើយពិតជាបានខ្ចីប្រាក់កូនក្តីខ្លួនប្រាកដមែន ដូច្នេះ តាមក្រឹត្យច្បាប់ ៣៨ក្រ.ច ចុងចម្លើយត្រូវមានកាតព្វកិច្ចសងប្រាក់ រួមទាំងការប្រាក់អោយកូនក្តីខ្លួនវិញ ។ នៅសាលាដំបូងចុងចម្លើយបានឆ្លើយទទួលស្គាល់ប្រាក់ជំពាក់កូនក្តីខ្លួនចំនួន ២.៤០០ដុល្លា តែមកដល់តុលាការកំពូល បែរជាថាជំពាក់តែ ៤០០ដុល្លាប៉ុណ្ណោះ ។

**សំណូមពរ :** សុំតម្កល់សាលដីកាសាលាឧទ្ធរណ៍ទុកជាបានការទាំងមូល ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យកា

-ក្រោយពីបានស្តាប់សេចក្តីថ្លែងការណ៍របស់គូភាគី និង មេធាវីតំណាងដោយអាណត្តិរបស់គូភាគី

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ១៨៧ ចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១៣ របស់ភាគីចុងចម្លើយ [redacted] តៃ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបាន តាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពសាលាជំរះក្តី និង មាត្រា ២៨៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

Scanned with CamScanner

-យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សំរេចតម្កល់សាលក្រមរដ្ឋប្បវេណីរបស់សាលាដំបូងខេត្តកំពង់ធំ ទុកជាបានការ ដោយទទួលស្គាល់កាតព្វកិច្ចរបស់ចុងចម្លើយ ដែលបានកើតឡើងពីកិច្ចសន្យា ចុះថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០១០ និង កិច្ចសន្យា ចុះថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០១០ មានទឹកប្រាក់សរុបចំនួន ២.៤០០ដុល្លា ហើយសំរេចអោយចុងចម្លើយទទួលខុសត្រូវសងប្រាក់ជំពាក់នេះទៅអោយដើមចោទវិញនោះ ជាការត្រឹមត្រូវហើយ ព្រោះថា ចុងចម្លើយបានទទួលស្គាល់ប្រាក់ជំពាក់ចំនួន ៤០០ដុល្លា តាមកិច្ចសន្យា ចុះថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០១០ រួចហើយ រីឯប្រាក់ជំពាក់ ២.០០០ដុល្លា តាមកិច្ចសន្យា ចុះថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០១០ ទោះបីចុងចម្លើយបានបដិសេធមិនទទួលស្គាល់បំណុលនេះក្តី តែបានទទួលស្គាល់ថា ពិតជាបានផ្តិតមេដៃលើកិច្ចសន្យានេះមែន ដែលជាហេតុធ្វើអោយចុងចម្លើយត្រូវមានបន្ទុកទទួលខុសត្រូវសំណងនេះ តាមបណ្តឹងទាមទាររបស់ដើមចោទ។ ប៉ុន្តែ ការដែលសាលាឧទ្ធរណ៍ទទួលស្គាល់កាតព្វកិច្ចរបស់ភាគីចុងចម្លើយ ដែលបានកើតឡើងពីកិច្ច-សន្យា ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០១០ មានទឹកប្រាក់កម្ចីចំនួន ២.០០០ដុល្លា ហើយសំរេចអោយចុងចម្លើយទទួលខុសត្រូវនោះ មិនទាន់មានមូលដ្ឋានច្បាស់លាស់គ្រប់គ្រាន់នៅឡើយទេ ពីព្រោះថា កិច្ចសន្យាចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០១០ នេះ ចុងចម្លើយមិនបានទទួលស្គាល់ទេ ហើយបានបដិសេធស្នាមមេដៃនៅលើកិច្ចសន្យានេះថា មិនមែនជាស្នាមមេដៃរបស់ខ្លួនទៀតផង។ម្យ៉ាងទៀត សំអាងហេតុក្នុងសាលក្រម និង សាលដីកាបានទទួលស្គាល់ថា ចុងចម្លើយធ្លាប់បានបង់ការប្រាក់អោយទៅដើមចោទចំនួន ២ខែ ប៉ុន្តែ នៅក្នុងការវិនិច្ឆ័យសេចក្តីមិនបានពិចារណាអំពីបញ្ហាការប្រាក់ដែលបានបង់រួចហើយនេះ នៅក្នុងសេចក្តីសំរេចផងទេ ដែលជាការធ្វើឱ្យបាត់បង់ផលប្រយោជន៍របស់ភាគីចុងចម្លើយ។

-យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ ០៨ក្រ៖ ចុះថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១៣ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវខ្លះ និង មិនត្រឹមត្រូវខ្លះ។

## ហេតុដូចនេះ

## វិនិច្ឆ័យសេចក្តី

១-ទទួលផ្នែកខ្លះ នៃបណ្តឹងសាទុក្ខលេខ ១៨៧ ចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១៣ របស់ភាគីចុងចម្លើយ ហ៊ុល តៃ។

២-តម្កល់សាលដីការដ្ឋប្បវេណីលេខ ០៨ក្រ៖ ចុះថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១៣ របស់សាលាឧទ្ធរណ៍ទុកជាបានការ លើកលែងតែសេចក្តីសំរេចត្រង់ចំណុចទី ២, ទី ៣ និង ទី ៤ នៃសាលក្រមរដ្ឋប្បវេណីលេខ ១៤"ឆ" ចុះថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០១១ របស់សាលាដំបូងខេត្តកំពង់ធំ ត្រូវបដិសេធចោលជាអសារបង់។

៣-បញ្ជូនសំណុំរឿងរដ្ឋប្បវេណីលេខ ១៣៩ ចុះថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០១៣ របស់តុលាការកំពូលទៅសាលា



Scanned with CamScanner

ឧទ្ធរណ៍ ដើម្បីជំនុំជំរះជាថ្មី លើសេចក្តីសំរេចត្រង់ចំណុចទី ២ ទី ៣ និង ទី ៤ នៃសាលក្រមរដ្ឋប្បវេណីលេខ ១៤"ឆ" ចុះថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០១១ របស់សាលាដំបូងខេត្តកំពង់ធំ ។

៤-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់គូភាគី ។

៥-សាលដីកានេះជំនុំជំរះ នៅថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៤ និង ប្រកាសជាសាធារណៈ នៅថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១៤ ។

| | | |
|---|---|---|
| ឯកឧត្តម | [redacted] | ប្រធាន |
| លោកស្រី | | ចៅក្រម |
| លោក | | ចៅក្រម |
| លោក | | ចៅក្រម |
| លោក | | ចៅក្រម |
| លោកស្រី | | ក្រឡាបញ្ជី |

---

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម ។
ភ្នំពេញ ថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០១៤
ក្រឡាបញ្ជី
[redacted]

បានឃើញ
ភ្នំពេញ ថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៤
ប្រធាន
[redacted]